# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ការិយាល័យសហចៅក្រមស៊ើបអង្កេត

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jun-2016, 13:43
CMS/CFO: Sann Rada

សំណុំរឿងលេខ ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស

## សារណាមិនមែនជាភាគីឆ្លើយតបទៅនឹងសេចក្តីអំពាវនាវឲ្យដាក់សារណាពីភាគីនៅក្នុងសំណុំរឿង ០០៣ និង ០០៤ និងអ្នកដែលមិនមែនជាភាគី

Oliver Windridge[1]

[1] ជាមន្ត្រីរងផ្នែកច្បាប់នៅអង្គជំនុំជម្រះតុលាការកំពូល តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី(ICTY)(ឆ្នាំ ២០០៤ ដល់បច្ចុប្បន្ន)។ ពីមុន ជាមន្ត្រីរងផ្នែកច្បាប់នៅអង្គជំនុំជម្រះតុលាការកំពូល និងអង្គជំនុំជម្រះសាលាដំបូង តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉ាវ៉ាន់ដា (ICTR) (ឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៤)។ ជាមេធាវីនៅតុលាការជាន់ខ្ពស់អង់គ្លេស និងវែល (មិនប្រកបវិជ្ជាជីវៈ ចូលជាសមាជិកមេធាវីនៅខែ មេសា ឆ្នាំ ២០០៧)។ ការយល់ឃើញដែលបានបង្ហាញនៅក្នុងសារណានេះគឺជាការយល់ឃើញរបស់អ្នកនិពន្ធ ហើយមិនមែនមានន័យថាឆ្លុះបញ្ចាំងពីការយល់ឃើញរបស់អង្គការសហប្រជាជាតិ ឬអង្គការណាផ្សេងទៀតដែលជាញាតិសម្ព័ន្ធរបស់អ្នកនិពន្ធឡើយ។

# មាតិកា

I. សេចក្តីផ្តើម
II. និយមន័យអំពីច្បាប់ទម្លាប់អន្តរជាតិ
III. ការលេចឡើងនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងលក្ខខណ្ឌតម្រូវត្រូវមាន"ជនស៊ីវិល"
IV. "ជនស៊ីវិល"នៅក្រោមច្បាប់សង្គ្រាម ធៀបជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ
V. សេចក្តីសន្និដ្ឋាន

ចំនួនពាក្យ៖ ២ ៩៩៩ (រាប់បញ្ចូលទាំងជើងទំព័រ)

## I. សេចក្តីផ្តើម

*បើសិនបើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតម្រូវឲ្យមានការវាយប្រហារមកលើ“ប្រជាជនស៊ីវិលណាក៏ដោយ” តើសមាជិកនៃកងកម្លាំងប្រដាប់អាវុធ អាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬទេ?*

១. សំណួរខាងលើមានលក្ខណៈសាមញ្ញនិយម មិនពិចារណាលើក្របខណ្ឌពេលវេលា និងលក្ខណៈនៃការវាយប្រហារឡើយ ប៉ុន្តែ ចំណុចសំខាន់ គឺត្រូវព្យាយាមឆ្លើយសំណួរខាងលើនេះ។ ដើម្បីឆ្លើយ សារណាមិនមែនជាភាគីនេះ ផ្តោតជាចម្បងលើលក្ខខណ្ឌតម្រូវត្រូវមាន“ជនស៊ីវិល”ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទម្លាប់អន្តរជាតិ នៅឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ដោយផ្តោតលើនិយមន័យអំពី “ជនស៊ីវិល” សារណានេះនឹងកំណត់ថាតើ“ការបោសសម្អាតយោធា”នឹងត្រូវលើកលែងពីការវិនិច្ឆ័យទោស ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬទេ។

២. សារណាមិនមែនជាភាគីនេះនឹងរំឭកឡើងវិញដោយសង្ខេបអំពី “ច្បាប់ទំនៀមទម្លាប់” និងការលេចឡើងនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជាពិសេស លក្ខខណ្ឌតម្រូវត្រូវមាន“ជនស៊ីវិល”។ បន្ទាប់មក សារណានេះនឹងពិចារណាលើភាពខុសគ្នាដ៏សំខាន់រវាងនិយមន័យអំពី“ជនស៊ីវិល”តាមច្បាប់សង្គ្រាម ជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ សារណានេះធ្វើសេចក្តីសន្និដ្ឋានថា នៅពេលដែលពិចារណាមូលហេតុដែលបង្កើតឲ្យមានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការប្រើប្រាស់ឧក្រិដ្ឋកម្មនេះបន្ទាប់ពីសង្គ្រាមលោកលើកទី ២ ច្បាប់ទម្លាប់អន្តរជាតិក៏គួរតែអនុញ្ញាតឲ្យមាននិយមន័យទូលំទូលាយអំពីពាក្យថា “ជនស៊ីវិល” ដោយរាប់បញ្ចូលជាជនស៊ីវិលទាំងសមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលមិនចូលរួមផ្ទាល់នៅក្នុងជម្លោះផងដែរ[2]។ សារណាមិនមែនជាភាគីនេះ គាំទ្រនិយមន័យទូលំទូលាយបំផុតតាមដែលអាចធ្វើទៅបានអំពីពាក្យនេះ ដើម្បីចៀសវាងស្ថានភាពមិនសមហេតុផល គឺថា បុគ្គលនានាអាចរងការវាយប្រហារដោយមូលហេតុផ្សេងៗដូចជា ជាតិពន្ធុ ឬសាសនា ហើយស្ថិតនៅក្នុងចន្លោះប្រហោងច្បាប់ដោយសារការងាររបស់គាត់ជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ចំណែកឯ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានបង្កើតឡើងដើម្បីការពារជនដែលឧក្រិដ្ឋកម្មសង្គ្រាមមិនអាចការពារ។

---

[2] គោលជំហរមួយរបស់សាស្ត្រាចារ្យ Antonio Cassese *សូមមើល* ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិទីក្រុងរ៉ូម I មតិយោបល់ ទំព័រ ៣៥៣ និង ៣៧៥ (ឆ្នាំ ២០០២)។

## II. និយមន័យអំពីច្បាប់ទម្លាប់អន្តរជាតិ

៣. អ.វ.ត.ក ធ្លាប់បានកំណត់និយមន័យច្បាប់ទម្លាប់អន្តរជាតិ ថាជា"អត្ថិភាពនៃទម្លាប់អនុវត្តន៍ "ទូទៅប្រកបដោយសង្គតិភាព និងរលូន"របស់រដ្ឋ ឬទស្សនៈច្បាប់ ពោលគឺ អ្វីដែលរដ្ឋនានាយកមកអនុវត្ត និងនិយាយនោះ តំណាងឱ្យច្បាប់"[3]។ អ.វ.ត.ក បានពន្យល់ថែមទៀតថា ទម្លាប់អនុវត្តន៍ជាច្រើនរបស់រដ្ឋពុំសូវភ្ជាប់មកជាមួយនូវការសន្មតជាមុនថា ទស្សនៈច្បាប់មានអត្ថិភាពឡើយ ហើយ "អំពើដែលពាក់ព័ន្ធ មិនត្រូវបានរាប់ថាត្រឹមតែទម្លាប់អនុវត្តន៍អចិន្ត្រៃយ៍ប៉ុណ្ណោះទេ ប៉ុន្តែអំពើទាំងនោះត្រូវតែជាទម្លាប់អនុវត្តន៍ ឬត្រូវបានយកមកអនុវត្តក្នុងលក្ខណៈអាចជាភស្តុតាងឱ្យគេមានជំនឿថា ទម្លាប់អនុវត្តន៍នេះជាកាតព្វកិច្ច តាមរយៈអត្ថិភាពនៃវិធាននៃច្បាប់ដែលតម្រូវឱ្យមានទម្លាប់អនុវត្តន៍នេះ"[4]។ រដ្ឋនានាតាមការឯកភាពរបស់ខ្លួន គឺជាអ្នកកំណត់ខ្លឹមសារនៃច្បាប់អន្តរជាតិ ហើយសេចក្តីសម្រេចរបស់តុលាការ ច្បាស់ជាបង្កើតឱ្យមាន"មធ្យោបាយបន្ទាប់បន្សំក្នុងការកំណត់អំពីវិធាននៃច្បាប់"[5]។ សារណានេះមិនស្វះស្វែងជំទាស់ជាមួយនឹងនិយមន័យនេះឡើយ ហេតុនេះមិនចាំបាច់ពិនិត្យថែមទៀតឡើយ ក្រៅពីថា ច្បាប់ទម្លាប់អន្តរជាតិ ចាំបាច់តម្រូវឱ្យបំពេញលក្ខខណ្ឌខ្ពស់ គឺថា ទម្លាប់អនុវត្តន៍ ប្រកបដោយសង្គតិភាព និងរលូនរបស់រដ្ឋ គឺជាលក្ខខណ្ឌតម្រូវគ្រប់គ្រាន់ហើយ។

## III. ការលេចឡើងនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងលក្ខខណ្ឌតម្រូវត្រូវមាន"ជនស៊ីវិល"

៤. មានកម្រងឯកសារយ៉ាងច្រើនសរសេរថា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"ជាទស្សនាទានមួយអាចមានឫសគល់តាំងពីសង្គ្រាមលោកលើកទី ១ នៅពេលដែលមហាអំណាចសម្ព័ន្ធមិត្តបានព្យាយាមពង្រីកច្បាប់សង្គ្រាមមានស្រាប់ឱ្យដល់ជនគ្រប់រូប មិនត្រឹមតែជនជាតិរបស់រដ្ឋបច្ចាមិត្តដូចជា សត្រូវ ឡើយ។ ការព្យាយាមលើកដំបូងទាំងនេះបានធ្វើឡើងជាពិសេសដើម្បីឆ្លើយតបទៅនឹងអំពើឃោរឃៅដែលគេបានរាយការណ៍ថា ចក្រភព Ottoman បានប្រព្រឹត្តឡើងមកលើជន

---

[3]សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ ៣៨) ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ៥៣ (សាលដីកាលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី III)។

[4] សាលដីកាលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី III កថាខណ្ឌ ៥៣។

[5] សាលដីកាលើសហឧក្រិដ្ឋកម្មរួមទម្រង់ទី III កថាខណ្ឌ ៥៣។ មាត្រា ៣៨(១)(ខ)នៃលក្ខន្តិកៈតុលាការយុត្តិធម៌អន្តរជាតិ ចែងថា "ទំនៀមទម្លាប់ ដែលជាភស្តុតាងអំពីការអនុវត្តជាទូទៅដែលគេទទួលយក គឺជាច្បាប់"។

ជាតិ Ottoman ដើមកំណើតអាមេរិក ហើយការព្យាយាមទាំងនេះអាចរកឃើញមានជាទូទៅដោយយោងលើ"ច្បាប់មនុស្សជាតិ"នៅក្នុងសន្ធិសញ្ញា Sévres ទោះបីជាមិនមានការវិនិច្ឆ័យទោសចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក៏ដោយ[6]។

៥. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានលេចឡើងម្តងទៀតនៅក្នុងធម្មនុញ្ញសាលាក្តីយោធាអន្តរជាតិនៅ Nuremberg ក្រោយសង្គ្រាមលោកលើកទី ២ ដើម្បីបញ្ចូលអំពើឧក្រិដ្ឋដែលមិនមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់សង្គ្រាមដែលមានស្រាប់ ឧទាហរណ៍ អំពើអមនុស្សធម៌មកលើជនស៊ីវិលដែលមិនមែនជាជនជាតិរបស់សត្រូវ[7]។ ហេតុនេះ ការបញ្ចូលឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងលក្ខន្តិកៈតុលាការយោធាអន្តរជាតិ អាចចាត់ទុកថាជាការពង្រីកការការពារឲ្យដល់ប្រជាជនស៊ីវិលដោយមិនគិតពីសញ្ជាតិឡើយ។ Egon Schwelb បានពន្យល់ពីសន្ទុះដែលជំរុញឲ្យមានវិធានការរៀបចំក្រមអំពីឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចខាងក្រោម៖

"ដោយសារអំពីឧក្រិដ្ឋកម្មមិនធ្លាប់មានពីមុនមកដែលរបបណាហ្ស៊ីស និងមហាអំណាចអាស៊ីសផ្សេងទៀត បានប្រព្រឹត្តឡើងមិនតែមកលើយុទ្ធជនសម្ព័ន្ធមិត្តប៉ុណ្ណោះទេ ប៉ុន្តែក៏មកលើប្រជាជនស៊ីវិលរបស់ប្រទេសដែលគេកាន់កាប់ និងប្រទេសរបស់អាស៊ីសខ្លួនឯងផងដែរ ទើបចាំបាច់ត្រូវតម្រូវថា ឧក្រិដ្ឋកម្មទាំងនេះមិនគប្បីបណ្តោយឲ្យរួចទោសឡើយ"[8]។

៦. ហេតុនេះ មាត្រា ៦(៣) នៃលក្ខន្តិកៈតុលាការយោធាអន្តរជាតិ បានកំណត់និយមន័យថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជា៖

...ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗទៀតដែលបានប្រព្រឹត្តមកលើប្រជាជនស៊ីវិលណាក៏ដោយ នៅមុនពេល ឬក្នុងអំឡុង

---

[6] ពាក្យទាំងនេះមានដំបូងបំផុតនៅក្នុងឯកសាររបស់ Marten ស្តីពីខចែងនៃអនុសញ្ញាទីក្រុងឡាអេ IV ឆ្នាំ ១៩០៧ ដែលគោរពច្បាប់ និងទំនៀមទម្លាប់សង្គ្រាមនៅលើគោក ដូចបានលើកយោងនៅក្នុងឯកសាររបស់ Payam Akhavan ចំណងជើង *ការផ្សះផ្សាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាមួយនឹងច្បាប់សង្គ្រាម* ទិនានុប្បវត្តិប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ទំព័រ ៦ និង ២២ (ឆ្នាំ ២០០៨)។

[7] Darryl Robinson *ការកំណត់និយមន័យ "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"នៅសន្និសីទទីក្រុងរ៉ូម* ទិនានុប្បវត្តិច្បាប់អន្តរជាតិរបស់អាមេរិក វ៉ុល ៩៣ លេខ ១ ទំព័រ ៤៤ (ឆ្នាំ ១៩៩៩)។

[8] Egon Schwelb ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សៀវភៅប្រចាំឆ្នាំចក្រភពអង់គ្លេសស្តីពីច្បាប់អន្តរជាតិ លើកទី ២៣ ឆ្នាំ ១៩៤៦ ១៧៨-២២៦ ទំព័រ ១៨៥។

ពេលសង្គ្រាម ឬការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនានៅក្នុងការអនុវត្ត ឬពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មណាដែលស្ថិតនៅក្នុងយុត្តាធិការរបស់សាលាក្តីនេះ ទោះថាបានរំលោភបំពាន ឬមិនបានរំលោភបំពានច្បាប់ជាតិរបស់ប្រទេសដែលឧក្រិដ្ឋកម្មនោះបានប្រព្រឹត្តឡើងក៏ដោយ”[9]។

៧. គេបានផ្តល់ទឡ្ហីករណ៍ថា ពាក្យថា “ជនស៊ីវិល” បានរក្សាទុកនៅក្នុងលក្ខន្តិកៈតុលាការយោធាអន្តរជាតិ ដោយទុកជាការយោគយល់មួយ ពីព្រោះថា ពាក្យនេះមានមូលដ្ឋានគ្រឹះរឹងមាំនៅក្នុងយុត្តិសាស្ត្រនេះ[10]។ ប៉ុន្តែ “យុត្តិសាស្ត្រ”ទាំងនេះ ហាក់ដូចជាសំដៅលើ *ច្បាប់សង្គ្រាម* ដែលពាក្យថា“ជនស៊ីវិល”មានបរិបទផ្សេងពីបរិបទដែលមាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដូចពិភាក្សាខាងក្រោមនេះ[11]។

៨. ហេតុនេះ ខ្លឹមសាររួមមានតាំងពីពេលបង្កើតឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោយសង្គ្រាមលោកលើកទី ១ និងការរៀបចំក្រមអំពីឧក្រិដ្ឋកម្មនេះនៅក្នុងលក្ខន្តិកៈសាលាក្តីយោធាអន្តរជាតិ និងសាលាក្តីផ្សេងទៀតក្រោយសង្គ្រាមលោកលើកទី ២។ ពេលនោះ មានតម្រូវការត្រូវដាក់ឱ្យទទួលខុសត្រូវចំពោះជនដែលរំលោភបំពានច្បាប់សង្គ្រាមដែលមានស្រាប់ ដែលចែងជាពិសេសអំពីសមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលចូលរួមក្នុងជម្លោះ និងជនដែលប្រព្រឹត្តអំពើឃោរឃៅដែលមិនមានចែងនៅក្នុងច្បាប់សង្គ្រាម។ ហេតុនេះ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានបំពេញចន្លោះប្រហោងនេះ និងពង្រឹងឧក្រិដ្ឋកម្មអន្តរជាតិឱ្យស្ថិតក្រោមការគ្រប់គ្រងរបស់សហគមន៍អន្តរជាតិ ដើម្បីទប់ស្កាត់របបនានា និងមេដឹកនាំនានាកុំឱ្យគេចចេញពីការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការវាយប្រហារមកលើជនណាម្នាក់។ ហេតុនេះ ការលេចចេញនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាឧក្រិដ្ឋកម្មតែឯង ត្រូវបានពិចារណាយ៉ាងត្រឹមត្រូវថាមិនអាចទប់ស្កាត់បានឡើយតាមរយៈ

[9] បទល្មើសនេះក៏មានបញ្ចូលនៅក្នុងមាត្រា ៥ (គ) នៃធម្មនុញ្ញទីក្រុងតូក្យូ និងមាត្រា II (១)នៃច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០។ ប៉ុន្តែ គួរកត់សម្គាល់ថា ខណៈដែលធម្មនុញ្ញ Nuremberg និងតូក្យូ បានតម្រូវថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវមានភស្តុតាងបញ្ជាក់ពីការជាប់ទាក់ទងជាមួយនឹងសង្គ្រាមឈ្លានពាន ឬឧក្រិដ្ឋកម្មសង្គ្រាមយ៉ាងណាក៏ដោយ ក៏លក្ខខណ្ឌតម្រូវបន្ថែមនេះមិនមែនចែងនៅក្នុងច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០។

[10] Darryl Robinson ការកំណត់និយមន័យ “ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ”នៅសន្និសីទទីក្រុងរ៉ូម ទិនានុប្បវត្តិអាមេរិកស្តីពីច្បាប់អន្តរជាតិ វ៉ុល ៩៣ លេខ ១ ទំព័រ ៤៤ (ឆ្នាំ ១៩៩៩)។

[11] ការងាររបស់គណៈកម្មការច្បាប់អន្តរជាតិ ចាត់តាំងដោយមហាសន្និបាទអង្គការសហប្រជាជាតិ ឱ្យបង្កើតគោលការណ៍ច្បាប់អន្តរជាតិដែលបានទទួលស្គាល់ និងពង្រឹងនៅក្នុងធម្មនុញ្ញ Nuremberg ហើយសាលក្រម គួរកត់សម្គាល់ផងដែរ។

ច្បាប់សង្គ្រាម ហើយអាចត្រូវចាត់ទុកថាជាការពង្រីកបទឧក្រិដ្ឋនៃអំពើឃោរឃៅទ្រង់ទ្រាយធំឱ្យហួសពីស្ថានភាពសង្គ្រាម ទៅដល់ស្ថានភាពពេលមានសន្តិភាព[12]។

៩. ការវិនិច្ឆ័យទោសជាក់ស្តែងចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងរឿងក្តីសង្គ្រាមលោកលើកទី ២ គាំទ្រការបកស្រាយដោយសេរីលើពាក្យថា"ជនស៊ីវិល"ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅក្នុងរឿងក្តីរបស់តុលាការកំពូលអាល្លឺម៉ង់ នៅភូមិភាគកាន់ដាប់ដោយចក្រភពអង់គ្លេស ចុងចោទត្រូវបានផ្តន្ទាទោសដោយសារតែចុងចោទបានកាត់ទោសប្រហារជីវិត និងបង្គាប់ឱ្យប្រហារជីវិតទាហានអាល្លឺម៉ង់ពីរនាក់។ ប៉ុន្តែ តុលាការដដែលនេះ ដោយកត់សម្គាល់ថា ឧក្រិដ្ឋកម្មទាំងនោះបានប្រព្រឹត្តឡើងមកលើទាហាន ទើបបានផ្តន្ទាទោសចុងចោទទាំងនោះពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[13]។ តុលាការនេះក៏បានផ្តន្ទាទោសចុងចោទម្នាក់ដោយសារចុងចោទនោះបានកាត់ទោសប្រហារជីវិតទាហានអាល្លឺម៉ង់ពីរនាក់ដែលបានប្រព្រឹត្តបទល្មើសបំបាក់ស្មារតីកងកម្លាំងប្រដាប់អាវុធ[14]។ សេចក្តីសម្រេចទាំងពីរនេះគាំទ្រតម្រូវការដែលត្រូវបកស្រាយដោយសេរីលើពាក្យថា"ជនស៊ីវិល"។ រឿងក្តីបន្ថែមទៀតដែលគាំទ្រការបកស្រាយបែបនេះដែរ រួមមាន រឿងក្តីបារាំង *Barbie* ដែលក្នុងនោះ តុលាការជាន់ខ្ពស់បារាំង បានសម្រេចថា សមាជិកនៃកងកម្លាំងតស៊ូអាចជាជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[15]។

---

[12] Payam Akhavan *ការផ្សះផ្សាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាមួយនឹងច្បាប់សង្គ្រាម* ទិនានុប្បវត្តិប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ ៦ ២២-៣៧ ទំព័រ ២២ (ឆ្នាំ ២០០៨)។

[13] តុលាការកំពូលអាល្លឺម៉ង់នៅភូមិភាគកាន់កាប់ដោយចក្រភពអង់គ្លេស សាលដីកា រឿងក្តីលេខ St S 111/48 ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៤៨ 1 ENTSCHEIDGUNGEN DES OBERSTEN GERICHTSHOFES DER BRITISCHEN ZONE IN STRAFSACHEN ទំព័រ ២១៩ និង ២២៨ (ឆ្នាំ ១៩៤៨) ដូចបានលើកយោងនៅក្នុងឯកសាររបស់ Ambos និង Wirth ចំណងជើង ច្បាប់បច្ចុប្បន្នស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ ការវិភាគបទបញ្ញាលេខ ១៥/២០០០របស់រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើត(UNTAET) ទិនានុប្បវត្តិវេទិកាច្បាប់ព្រហ្មទណ្ឌ វ៉ុល ១៣ លេខ ១ ទំព័រ ២៣ (ឆ្នាំ ២០០២)។

[14] តុលាការកំពូលអាល្លឺម៉ង់នៅភូមិភាគកាន់កាប់ដោយចក្រភពអង់គ្លេស សាលដីកា រឿងក្តីលេខ StS 309/49 ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៤៩ 2 ENTSCHEIDGUNGEN DES OBERSTEN GERICHTSHOFES DER BRITISCHEN ZONE IN STRAFSACHEN ទំព័រ ២៣១ (ឆ្នាំ ១៩៤៨) ដូចបានលើកយោងនៅក្នុងឯកសាររបស់ Ambos និង Wirth ចំណងជើង ច្បាប់បច្ចុប្បន្នស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ ការវិភាគបទបញ្ញាលេខ ១៥/២០០០របស់រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើត (UNTAET) ទិនានុប្បវត្តិវេទិកាច្បាប់ព្រហ្មទណ្ឌ វ៉ុល ១៣ លេខ ១ ទំព័រ ២៣ (ឆ្នាំ ២០០២)។

[15] រឿងក្តី *Barbie* , 78 I.L.R 140 (តុលាការជាន់ខ្ពស់បារាំង)។

១០. ដំណាក់កាលបន្ទាប់នៅក្នុងការវិវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺដើរហួសពីរយៈពេលពាក់ព័ន្ធពី ឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ រហូតដល់ទសវត្សរ៍ដើមឆ្នាំ ១៩៩០។ ដោយសារបានបង្កើតតុលាការ ICTY និង ICTR ទើបឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាថ្មីម្តងទៀតមានចែងនៅក្នុងគន្លឹលក្ខន្តិកៈ របស់តុលាការទាំងនេះ[16]។ តុលាការ ICTY និង ICTR បានពិចារណាយ៉ាងលម្អិតអំពីពាក្យថា "ជនស៊ីវិល"នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ សេចក្តីសន្និដ្ឋានរបស់តុលាការទាំងនេះឃើញ មានការបែកចែកយ៉ាងច្បាស់រវាងនិយមន័យអំពី "ជនស៊ីវិល"នៅក្នុងឧក្រិដ្ឋកម្មសង្គ្រាម ជាមួយនឹង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហេតុនេះហើយទើបមានការបកស្រាយដោយសេរីយ៉ាងច្បាស់អំពី ពាក្យថា "ជនស៊ីវិល"។

១១. តាមពិត តុលាការ ICTY កំណត់ថា ច្បាប់សង្គ្រាម អាចចាត់ទុកថាជា*ការណែនាំ* អំពីនីត្យានុកូល ភាពនៃអំពើក្នុងអំឡុងពេលជម្លោះ និងការវាយប្រហារសំដៅលើ"ប្រជាជន" ដោយមិនប្រើប្រាស់ និយមន័យអំពីប្រជាជនតាមច្បាប់សង្គ្រាមឡើយ។ ឧទាហរណ៍ នៅក្នុងរឿងក្តី *Gotovina* អង្គ ជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានសម្រេចថា "ការបញ្ចូលគ្នានូវមាត្រាដាច់ដោយឡែក ដែលចែងពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម គឺច្បាស់ជាមិនមែនការបញ្ចូលគ្នា ដោយចៃដន្យឡើយ ប៉ុន្តែបង្ហាញថា របបឧក្រិដ្ឋកម្មទាំងពីរនេះមានអត្ថិភាពដាច់ដោយឡែក និងឯក រាជ្យ"[17]។

១២. ចំពោះការបកស្រាយដោយសេរីលើពាក្យថា "ជនស៊ីវិល" តុលាការ ICTY បានកំណត់ថា ប្រជា ជនអាច"ភាគច្រើន"មានលក្ខណៈជាជនស៊ីវិល ហើយធ្វើការបកស្រាយយ៉ាងទូលាយអំពីពាក្យថា "ជនស៊ីវិល"[18]។ តុលាការនេះក៏យល់ឃើញថា នៅក្នុងចំណោមប្រជាជនស៊ីវិល វត្តមានរបស់

---

[16] លក្ខន្តិកៈតុលាការ ICTR, ICTY និង SCSL សុទ្ធតែប្រើប្រាស់ពាក្យថា "មកលើប្រជាជនស៊ីវិលណាក៏ដោយ" ដោយមិនបាន ពន្យល់ថែមទៀតអំពីពាក្យថា "ស៊ីវិល"ឡើយ។ មាត្រា ៥ នៃលក្ខន្តិកៈ ICTY ។ មាត្រា ៣ នៃលក្ខន្តិកៈ ICTR ។ *សូមមើលផង ដែរ* មាត្រា ២ នៃលក្ខន្តិកៈ SCSL និងក្រោយមក មាត្រា (៧)(១)នៃ លក្ខន្តិកៈទីក្រុងរ៉ូមរបស់ ICC ដែលប្រើប្រាស់ផងដែរនូវ ពាក្យថា ("មកលើប្រជាជនស៊ីវិលណាក៏ដោយ")។

[17] សេចក្តីសម្រេចលើញត្តិមួយចំនួនដែលជំទាស់ជាមួយនឹងយុត្តាធិការ រឿងក្តី *Gotovian* (IT-06-90-PT) អង្គជំនុំជម្រះសាលា ដំបូង ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ កថាខណ្ឌ ២៦។

[18] សូមមើល សាលក្រម Tadic (IT-94-1-T) (ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ១៩៩៧) កថាខណ្ឌ ៦៤-៦៤២។ រឿងក្តី *Kordic និង Cerkez* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ១៨០។ រឿងក្តី *Naletilic និង Martinovic* (អង្គ ជំនុំជម្រះសាលាដំបូង) ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ កថាខណ្ឌ ២៣៥។

បុគ្គលដែលមិនស្ថិតនៅក្នុងនិយមន័យអំពីជនស៊ីវិល គឺមិនដកហូតលក្ខណៈជាជនស៊ីវិលពីប្រជាជននោះបានឡើយ[19] ហើយវត្តមានរបស់ជនដែលចូលរួមក្នុងជម្លោះ មិនដកហូតលក្ខណៈជាជនស៊ីវិលពីប្រជាជនឡើយ[20]។ តុលាការនេះក៏បានបញ្ជាក់យ៉ាងច្បាស់ថែមទៀតថា "ជនស៊ីវិល" រាប់បញ្ចូលទាំងជនដែលជាសមាជិកនៃចលនាតស៊ូ និងអតីតយុទ្ធជនដែលលែងចូលរួមសកម្មភាពអរិភាព គឺស្របតាមរឿងក្ដីសង្គ្រាមលោកលើកទី ២ ដែលបានពិនិត្យខាងលើ[21]។ ត្រូវបកស្រាយដោយសេរីលើពាក្យថា ប្រជាជនស៊ីវិល[22]។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺការពារប្រជាជនស៊ីវិលណាក៏ដោយ[23]។

១៣. ស្រដៀងគ្នានេះដែរ នៅតុលាការ ICTR និយមន័យទូលាយអំពីជនស៊ីវិល អាចអនុវត្តបាន[24]។ នៅក្នុងរឿងក្ដី *Akayesu* អង្គជំនុំជម្រះសាលាដំបូងរបស់តុលាការ ICTR បានបញ្ជាក់ថា "សមាជិកនៃប្រជាជនស៊ីវិល គឺជាប្រជាជនដែលមិនចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពអរិភាព រួមមានសមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលបានទម្លាក់អាវុធ និងជនដែលស្ថិតក្នុងសភាពបាត់បង់សមត្ថភាពប្រយុទ្ធដោយសារជំងឺ របួស ការឃុំខ្លួន ឬមូលហេតុណាផ្សេងទៀត"[25]។ តុលាការ

---

[19] រឿងក្ដី *Jelisic* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥៤។

[20] រឿងក្ដី រដ្ឋអាជ្ញាតទល់នឹង *Kupreskic និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-95-16 (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ៥៤៩។ រឿងក្ដី *Blaskic* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ កថាខណ្ឌ ២១៤។

[21] រឿងក្ដី *Blaskic* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ កថាខណ្ឌ ២១៤។ រឿងក្ដី *Jelisic* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥៤។ រឿងក្ដី *Kordic និង Cerkez* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ១៨០។ រឿងក្ដី *Naletilic និង Martinovic* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ កថាខណ្ឌ ២៣៥។

[22] រឿងក្ដី *Kupreskic និងអ្នកផ្សេងទៀត* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ៥៤៧-៥៤៩។ រឿងក្ដី *Jelisic* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៥៤។

[23] រឿងក្ដី *Vasiljevic* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០២ កថាខណ្ឌ ៣៣។

[24] រឿងក្ដី *Kayishema និង Ruzindana* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ១២៧-១២៩។

[25] ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥៨២។ *សូមមើលផងដែរ* រឿងក្ដី *Rutaganda* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៧២។ រឿងក្ដី *Musema* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ២០៧។

ICTR ក៏បានបញ្ជាក់ផងដែរថា វត្តមានរបស់ជនដែលមិនមែនជាជនស៊ីវិល មិនដកហូតលក្ខណៈជាជនស៊ីវិលពីប្រជាជននោះឡើយ[26]។

១៤. យុត្តិសាស្ត្ររបស់ តុលាការ ICTY និង ICTR កើតឡើងបន្ទាប់ពីរយៈកាលពាក់ព័ន្ធនៅក្នុងបញ្ហាចោទនេះ ប៉ុន្តែ យុត្តិសាស្ត្រនេះបង្ហាញពីស្ថានភាពច្បាប់ទម្លាប់ដែលបានបង្កើតយុត្តិសាស្ត្រនេះ ហេតុនេះអាចអនុវត្តបានចំពោះរយៈកាលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។

១៥. ជាសេចក្តីសន្និដ្ឋាន មានផ្លូវបំបែកច្រមុះជ្រូកចេញពីផ្លូវធំ ឬក៏យ៉ាងហោចណាស់មានបន្ថែមចំណែកផ្លូវលើផ្លូវធំនេះចាប់តាំងពីសង្គ្រាមលោកលើកទី ១ មក។ ពីមុននោះ ផ្លូវធំនេះជាគោលការណ៍មានចំណែកផ្លូវតែមួយជួរទេ គឺច្បាប់សង្គ្រាម តែប៉ុណ្ណោះ។ មិនមានការពិចារណាថា ជនស៊ីវិល គឺជាជនរងគ្រោះនៃអំពើឃោរឃៅឡើយ ប៉ុន្តែ មានការផ្តោតលើអ្វីដែលចាត់ទុកថាជាទង្វើសមហេតុផលនៅក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធអន្តរជាតិ រួមមានទង្វើដែលប្រព្រឹត្តមកលើយុទ្ធជនដែលធ្លាក់ចូលក្នុងដៃសត្រូវ។ ចំណែកផ្លូវថ្មីៗនៅលើផ្លូវធំនៃច្បាប់អន្តរជាតិ ត្រូវបានបន្ថែមក្រោយពីលេចចេញនូវសេចក្តីលម្អិតអំពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយកងកម្លាំងប្រដាប់អាវុធ តាមរយៈរបបណាហ្ស៊ីស មិនមែនមកលើកងកម្លាំងប្រដាប់អាវុធរបស់សត្រូវទេ ប៉ុន្តែបែរជាមកលើជនស៊ីវិលទៅវិញ។

## IV. “ជនស៊ីវិល”នៅក្រោមច្បាប់សង្គ្រាម ធៀបជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

១៦. នៅពេលដែលពិចារណាលើពាក្យថា“ជនស៊ីវិល”នៅក្រោមច្បាប់សង្គ្រាម ធៀបជាមួយនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សំខាន់គឺមិនត្រូវពឹងផ្អែកលើពាក្យនេះដូចឃើញមាននៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិឡើយ។ ការប្រើប្រាស់ពាក្យថា “ជនស៊ីវិល” មានន័យផ្សេងៗគ្នាទៅតាមឧក្រិដ្ឋកម្មផ្សេងៗគ្នា។ បញ្ហាប្រើប្រាស់ច្បាប់សង្គ្រាម ជាការណែនាំដើម្បីកំណត់និយមន័យអំពី“ជនស៊ីវិល” គឺថា តាមច្បាប់សង្គ្រាម ការសម្លាប់ជនស៊ីវិល មិនមែនប្រាកដថាជាការធ្វើមនុស្សឃាតឡើយ ពីព្រោះថា ការសម្លាប់នេះអាចជាផ្នែកមួយនៃការខូចខាតជាឧបទ្ទវហេតុមិនជ្រុលហួសដែល

[26] រឿងក្តី *Akayesu* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥៨២។ *សូមមើលផងដែរ* រឿងក្តី *Rutaganda* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៧២។ រឿងក្តី *Musema* (អង្គជំនុំជម្រះសាលាដំបូង) ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០០០ កថាខណ្ឌ ២០៧។

បណ្ដាលមកពីការវាយប្រហារទៅលើគោលដៅយោធាណាមួយ[27]។ ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ វិញ ការសម្លាប់មិនអាចធ្វើយុត្តិកម្មបានឡើយថាជាផ្នែកមួយនៃការខូចខាតជាឧបទ្ទវហេតុ។ ចំពោះឧក្រិដ្ឋកម្មសង្គ្រាម ភាពខុសគ្នានេះគឺមានសារៈសំខាន់ ពីព្រោះថា វាបង្ហាញពីការប្រព្រឹត្តិខុសគ្នាមកលើយុទ្ធជន និងអ្នកដែលមិនមែនជាយុទ្ធជន។ ការបែងចែងភាពខុសគ្នានេះគឺមិនច្បាស់លាស់ខ្លាំងបែបនេះទេសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមពិត មិនមែនសំដៅលើ "ជនស៊ីវិល"ឡើយ ប៉ុន្តែ សំដៅលើ "ប្រជាជនស៊ីវិល" គឺមានភាពខុសគ្នាតិចតួច ប៉ុន្តែសំខាន់ចំពោះច្បាប់មនុស្សធម៌អន្តរជាតិ ដែលសំដៅលើបុគ្គលនានា ជាជាងលើប្រជជន។ មិនមានមូលហេតុថា "ប្រជាជនស៊ីវិល"មិនអាចរាប់បញ្ចូលទាំងជនដែលស្ថិតនៅក្នុងកងកម្លាំងប្រដាប់អាវុធឡើយ ពីព្រោះថា មានគ្រូបង្រៀន ឬវេជ្ជបណ្ឌិត។ តាមពិត រឿងសំខាន់ដែលថា "ជនស៊ីវិល"មិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ" គឺជាទស្សនាទានមួយនៃឧក្រិដ្ឋកម្មសង្គ្រាមដែលមិនអនុវត្តជាស្វ័យប្រវត្តិចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។

## V. <u>សេចក្ដីសន្និដ្ឋាន</u>

១៧. តុលាការ ICTY បានបញ្ជាក់ថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាការវាយប្រហារយ៉ាងធ្ងន់ធ្ងរមកលើសេចក្ដីថ្លៃថ្នូរមនុស្សជាតិ មកលើសញ្ញាណអំពីភាពជាមនុស្ស។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បណ្ដាលឲ្យប៉ះពាល់ ឬគួរតែប៉ះពាល់ដល់មនុស្សជាតិគ្រប់រូប មិនថាជនជាតិណាក៏ដោយ ក្រុមជាតិពិន្ទុណាក៏ដោយ ឬនៅកន្លែងណាក៏ដោយ[28]។

១៨. ហេតុនេះ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អាចបែងចែកឲ្យខុសពីឧក្រិដ្ឋកម្មសង្គ្រាម ជាពិសេសតាមរយៈការពង្រីកការការពារឲ្យដល់ប្រជាជនស៊ីវិល ដោយមិនគិតពីឋានៈជាយុទ្ធជនឡើយ ពីព្រោះថា វាពាក់ព័ន្ធនឹងការការពារប្រជាជន មិនមែនត្រឹមតែកងកម្លាំងប្រដាប់អាវុធឡើយ។ ដូច្នេះ ការប្រើ

[27] សូមមើលឧទាហរណ៍ មាត្រា ៥១(៥)(ខ)នៃអនុសញ្ញាទីក្រុងហ្សឺណែវ ពិធីសារ I ។

[28] មតិយោបល់ផ្ទុយរួមគ្នារបស់ចៅក្រម McDonald និងចៅក្រម Vohrah, រឿងក្ដី *Erdemović* (IT-96-22-A) អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ១៩៩៧ កថាខណ្ឌ ២១។

ប្រាស់ពាក្យថា "ជនស៊ីវិល"អាចមើលឃើញយ៉ាងត្រឹមត្រូវថាជា "កេរដំណែល"ដើមមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងច្បាប់សង្គ្រាម[29]។

១៩. ប្រសិនបើមិនរាប់បញ្ចូលសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ជា "ជនស៊ីវិល"នោះទេ គឺពិតជាបង្កើតឲ្យមានចន្លោះប្រហោងនៅក្នុងវិធានការការពារសមាជិកនៃកងកម្លាំងប្រដាប់អាវុធ។ ដោយពិនិត្យឃើញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានរៀបចំជាក្រមដើម្បីភ្ជិតចន្លោះប្រហោងនៅក្នុងច្បាប់អន្តរជាតិក្នុងគោលបំណងការពារជនគ្រប់រូប ទើបហាក់ដូចជាមិនសមហេតុផលឡើយ ប្រសិនបើបង្កើតឲ្យមានចន្លោះប្រហោងដោយសារការបកស្រាយក្នុងន័យចង្អៀតអំពីពាក្យថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ដើម្បីគាំទ្រគោលជំហរនេះ ដូចបានបង្ហាញខាងលើ សាលាក្តីសង្គ្រាមលោកលើកទី ២ នានា បានចងក្រងនូវរឿងក្តីច្បាប់ទំនៀមទម្លាប់ដែលបានតម្កល់ការផ្តន្ទាទោសក្នុងករណីដែលជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាទាហាន។ នេះគឺជាគោលជំហរមួយដែលមិនមានការជំទាស់ឡើយនៅត្រឹមឆ្នាំ ១៩៧៥។

២០. តាមពិត ប្រសិនបើដកសមាជិកនៃកងកម្លាំងប្រដាប់អាវុធចេញពីជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយគ្រាន់តែថាពួកគាត់មានការងារវិជ្ជាជីវៈបែបនោះ គឺមិនត្រឹមតែបញ្ចូលគ្នារវាងនិយមន័យនៅក្នុងឧក្រិដ្ឋកម្មសង្គ្រាម ជាមួយនឹងនិយមន័យនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិប៉ុណ្ណោះទេ ប៉ុន្តែជាក់ស្តែងក៏បានដកឋានៈជាជនរងគ្រោះបែបនេះដោយផ្អែកលើការងារវិជ្ជាជីវៈផងដែរ ចំណែកឯ អ្នកមានការងារវិជ្ជាជីវៈផ្សេងទៀតទាំងអស់ ត្រូវបានការពារទៅវិញ។ ច្បាស់ណាស់ នៅពេលដែលជនម្នាក់ធ្វើជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ទង្វើរបស់គាត់ត្រូវគ្រប់គ្រងដោយច្បាប់សង្គ្រាម ប៉ុន្តែ នេះមិនគួរមានន័យថា គាត់បាត់បង់ឋានៈជាជនរងគ្រោះសក្តានុពលនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។

២១. ដំណោះស្រាយ ដោយផ្អែកលើច្បាប់ទម្លាប់អន្តរជាតិ នៅចន្លោះឆ្នាំ ១៩៧៥ ដល់ ឆ្នាំ ១៩៧៩ គឺត្រូវចាត់ទុកថា សមាជិកនៃកងកម្លាំងប្រដាប់អាវុធ គឺជាជនស៊ីវិល នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ លើកលែងតែពេលដែលគេចូលរួមផ្ទាល់នៅក្នុងជម្លោះ។ ក្នុងករណីដែលចូលរួមក្នុងជម្លោះវិញ សមាជិកនៃកងកម្លាំងប្រដាប់អាវុធ ត្រូវបានការពារតាមច្បាប់សង្គ្រាម។ សេណារីយ៉ូនេះ

---

[29] Ambos និង Wirth ច្បាប់បច្ចុប្បន្នស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ៖ ការវិភាគបទបញ្ញាលេខ ១៥/២០០០របស់រដ្ឋបាលបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅទីម័រខាងកើត (UNTAET) ទិនានុប្បវត្តិវេទិកាច្បាប់ព្រហ្មទណ្ឌ វ៉ុល ១៣ លេខ ១ ទំព័រ ៣ (ឆ្នាំ ២០០២)។

អនុញ្ញាតឲ្យការពារទាំងស្រុងដល់សមាជិកនៃកងកម្លាំងប្រដាប់អាវុធ ប្រសិនបើពួកគាត់ត្រូវរបប ណាមួយដាក់គោលដៅមួយនៃការវាយប្រហារជាទូទៅ និងជាប្រព័ន្ធដោយមូលហេតុផ្សេងៗ រួម មាន មូលហេតុជាតិពិន្ទុ ឬសាសនា (ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) ឬនៅពេលដែលពួកគាត់ចូល រួមក្នុងជម្លោះប្រដាប់អាវុធអន្តរជាតិ ឬមិនមែនអន្តរជាតិ (ឧក្រិដ្ឋកម្មសង្គ្រាម)។ សេណារីយ៉ូនេះក៏ ស្របតាមស្មារតីនៃការបង្កើតឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការអនុវត្តច្បាប់ឧក្រិដ្ឋកម្មនេះរហូត ដល់ឆ្នាំ ១៩៧៥ ផងដែរ។